# សេចក្តីអំពាវនាវ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ សុំរាជរដ្ឋាភិបាលខ្មែរតម្លើងប្រាក់ខែជូនមន្ត្រីរដ្ឋការ គ្រូបង្រៀន ប៉ូលិស ទាហាន ឲ្យល្មមចិញ្ចឹមជីវិតបាន

**Website: www.hoksavann.org**

ថ្ងៃទី២៥ ធ្នូ ២០០៤

មនុស្សគ្រប់រូបក្មេងចាស់ប្រុសស្រី រស់នៅបានដោយអាស្រ័យចំណីអាហារបរិភោគ, សំលៀកបំពាក់ស្លៀកពាក់, ទីលំនៅសំរាប់ជ្រកនៅ និងប្រដាប់ប្រដាប្រើប្រាស់, ថ្នាំកែរោគពេលមានជម្ងឺ ដែលព្រះពុទ្ធសាសនាពោលថា បព្វជិតនិងគ្រហស្ថរស់នៅដោយអាស្រ័យបច្ច័យ៤ និងពោលថាសត្វទាំងឡាយរស់នៅដោយសារអាហារជាដើម ។ ប្រជាពលរដ្ឋខ្មែរទូទៅរស់នៅដោយប្រកបមុខរបរផ្សេងៗ ចំណែកអ្នករដ្ឋការទូទៅរស់នៅដោយអាស្រ័យប្រាក់ខែ ។ ជីវភាពរបស់ប្រជាពលរដ្ឋ បើចំណូលថវិកាពុំបានគ្រប់គ្រាន់ទេ ក៏ពុំអាចរស់នៅចិញ្ចឹមគ្រួសារកូនចៅបានឡើយ ក៏ដូចជាអ្នករដ្ឋការគ្រប់តំណែង សង្ឃឹមតែទៅលើប្រាក់ខែ ឬប្រាក់បៀវត្សរ៍តែម្យ៉ាង បើប្រាក់ខែនោះមានកម្រឹតទាបពេក ក៏ពុំអាចចិញ្ចឹមជីវិតបានដែរ ។ សព្វថ្ងៃនេះនៅប្រទេសកម្ពុជា ប្រាក់ខែរបស់អ្នករដ្ឋការជាន់ទាប គ្រូបង្រៀន ប៉ូលិស ទាហាន មានកម្រឹតទាបណាស់ ពុំអាចរស់នៅបានឡើយ ។ អ្នករដ្ឋការខ្លះឆ្លៀតពេលម៉ោងធ្វើការ ទៅធ្វើការ ផ្សេងទៀត ដើម្បីរកកំរៃខាងក្រៅយកមកបង្គ្រប់ ទើបជីវិតរស់នៅបាន ជាពិសេសគ្រូបង្រៀន ។ មិនគួរបន្ទោសគ្រូបង្រៀន ថាលក់ស្ករគ្រាប់លក់ក្រដាស់មេរៀន ដើម្បីរកប្រាក់ខាងក្រៅនោះទេ ព្រោះគ្រូបង្រៀនខ្លះមានកូនច្រើន បើមិនឆ្លៀតរកប្រាក់ខាងក្រៅទេ កូនត្រូវស្លាប់ ។ គួរបន្ទោសអ្នកឲ្យប្រាក់ខែតិចវិញ ព្រោះបើឲ្យប្រាក់ខែច្រើនល្មមចិញ្ចឹមជីវិតបាន សកម្មភាពបែបនេះពិតជាពុំកើតមានឡើយ ។ គុណភាពនៃការសិក្សារបស់សិស្សត្រូវចុះខ្សោយ ដោយគ្រូពុំមានកម្លាំងផ្លូវចិត្តក្នុងការបង្រៀន ដោយសារជីវភាពទន់ខ្សោយ ។ យុវជននិងយុវនារីជាធនធានរបស់សង្គម ជាអនាគតរបស់ប្រទេស គួរបង្កើនគុណភាពនៃការសិក្សាឲ្យមានកម្រឹតខ្ពស់ ។

នៅដើមឆ្នាំ២០០៥នេះ រាជរដ្ឋាភិបាលខ្មែរបានតម្លើងប្រាក់ខែខ្លះដល់មន្ត្រីរដ្ឋការ គ្រូបង្រៀន ប៉ូលិស ទាហាន ប៉ុន្តែការតម្លើងនេះមានចំនួនតិចណាស់ ។ បើគិតជាប្រាក់ខែអ្នករដ្ឋការតូចតាច មានគ្រូបង្រៀនជាដើម មានចំនួន៣០, ៤០ដុល្លារក្នុងមួយខែ ដូច្នេះក្នុងមួយថ្ងៃ ចាយបានតែមួយដុល្លារសំរាប់គ្រួសារទាំងមូល ។ កាលពីមុនឆ្នាំ១៩៧០ បើប្តីធ្វើគ្រូ រដ្ឋផ្តល់ប្រាក់ខែឲ្យប្រពន្ធដែរ ។ ឥឡូវនេះប្រាក់ខែតិចផង ថែមទាំងបើកមិនទៀងទាត់ផង តើគ្នាពិបាកយ៉ាងណា ។ ពុំស៊ីគ្នានឹងព្រឹទ្ធសភា រដ្ឋសភា និងរដ្ឋមន្ត្រីមានប្រាក់ខែដ៏ខ្ពស់រាប់ពាន់ដុល្លារ ចំណែករដ្ឋការតូចតាចមានប្រាក់ខែទាបបំផុត ស្ទើរតែពុំអាចរស់បាន ។ គ្រាន់តែគ្រូបង្រៀនឆ្លៀតរកស៊ីខាងក្រៅ ដូចជាឆ្លៀតរកស៊ីម៉ូតូឌុបជាដើម គេបន្ទោសគ្រូ គឺគេឲ្យតែគ្រូទាំងនោះបង្រៀនសិស្ស ទោះបីត្រូវស្លាប់ដោយអត់អាហារ គេពុំយកចិត្តទុកដាក់ឡើយ ។ ដូច្នេះគេពុំគួរដាក់កំហុសខ្លាំងពេលទៅលើអ្នករដ្ឋការតូចតាច ដែលប្រព្រឹត្តអំពើពុករលួយដើម្បីឲ្យជីវិតរស់ឡើយ គេគួរដាក់កំហុសឲ្យខ្លាំងចំពោះមន្ត្រីជាន់ខ្ពស់ ដែលប្រព្រឹត្តអំពើពុករលួយយ៉ាងខ្លាំងក្លា យកមានយកបានមានប្រាក់ខែរាប់សែនរាប់លានដុល្លារ លើគំនរទុក្ខវេទនារបស់ប្រជាពលរដ្ឋ និងអ្នករដ្ឋការតូចតាច ។ ដូច្នេះហើយបានជាច្បាប់ប្រឆាំងនឹងអំពើពុករលួយ ជាច្រើនឆ្នាំមកហើយពុំព្រមចេញរួចសោះ ។ ដើម្បីកំចាត់អំពើពុករលួយឲ្យដល់ឫសគល់ អ្នករដ្ឋការជាន់ខ្ពស់មុនឡើងកាន់តំណែង ត្រូវប្រកាសទ្រព្យសម្បត្តិដែលខ្លួនមាន ។ មួយទៀតបើបោសសំអាតអំពើពុករលួយ គេមិនត្រូវបោសសំអាតពីក្រោមទេ គឺគេត្រូវបោសសំអាតពីលើមកក្រោម ។ កន្លងមក គេមិនបោសសំអាតថ្នាក់លើ ដែលគ្រាន់តែស៊ីញ្ញេមួយខ្ទាច់ឲ្យវិនិយោទុន បានប្រាក់រាប់សែនរាប់លាន ហើយកាប់ឈើបង្ក្រាបបានតែអ្នកតូចតាច ត្រង់អ្នកកាប់ឈើរាប់ពាន់រាប់ម៉ឺនម៉ែត្រគីប គេបង្ក្រាបពុំបានឡើយ ។

តីបំផុត សូមអំពាវនាវដល់រាជរដ្ឋាភិបាលខ្មែរ សូមតម្លើងប្រាក់ខែដល់មន្ត្រីរដ្ឋការតូចតាច គ្រូបង្រៀន ប៉ូលិស ទាហាន ឲ្យបានច្រើនជាងក្នុងគំរោងនេះទៀត ឲ្យអ្នករដ្ឋការទាំងនោះរស់បាន ដើម្បីបំរើជាតិឲ្យមានប្រសិទ្ធិភាព ។ នៅពេលដែលទំនិញសព្វសារពើឡើងថ្លៃ ចំណែកប្រាក់ខែពុំឡើងនៅដដែល ឬឡើងតែបន្តិចបន្តួច នោះជីវិតរបស់អ្នករដ្ឋការទាំងនោះ ពុំអាចរស់បានឡើយ ។ បើយកប្រាក់ខែពីអំពើពុករលួយមកតម្លើងប្រាក់ខែឲ្យអ្នករដ្ឋការតូចតាចទាំងនោះ ក៏បានយ៉ាងបរិបូណ៌ ។ សព្វថ្ងៃនេះ ប្រទេសអ្នកផ្តល់អំណោយទាន ឃ្លាំមើលយ៉ាងហ្មត់ចត់ចំពោះរាជរដ្ឋាភិបាលខ្មែរ តើអំណោយទាននោះបានដល់ដៃប្រជាពលរដ្ឋក្រីក្រនិងអ្នករដ្ឋការតូចតាចឬទេ ។៚